**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មាធិការជាតិភាសាខ្មែរ**

## បទបញ្ជាផ្ទៃក្នុង
## នៃគណៈកម្មាធិការជាតិភាសាខ្មែរ

**ប្រការ ១.-**

បទបញ្ជាផ្ទៃក្នុងនេះ ធ្វើឡើងស្របតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។

**ប្រការ ២.-**

គណៈកម្មាធិការជាតិភាសាខ្មែរ សរសេរកាត់ថា គ.ជ.ភ.ខ. មានភារកិច្ចដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យយោងខាងលើហើយត្រូវទទួលភារកិច្ចសម្រេចពីកម្ពីពាក្យផងដែរ ដោយបញ្ហានេះមានទំនាក់ទំនងជាមួយការបង្កើតពាក្យ។

**ប្រការ ៣.-**

ប្រធាននៃ គ.ជ.ភ.ខ. ជាអធិបតីក្នុងសម័យប្រជុំពេញអង្គ។ អនុប្រធានអចិន្ត្រៃយ៍ អាចជាប្រតិភូទទួលសិទ្ធិពីប្រធានដើម្បីដឹកនាំការប្រជុំប្រចាំថ្ងៃ ឬ ធ្វើជាប្រធានប្រជុំផ្សេងៗនៃ គ.ជ.ភ.ខ.។ ក្នុងករណីអនុប្រធានអចិន្ត្រៃយ៍អវត្តមាន អនុប្រធានត្រូវបំពេញភារកិច្ចជំនួស។ ប្រសិនបើអនុប្រធានអវត្តមានផងដែរ ការគ្រប់គ្រងសម័យប្រជុំត្រូវធ្វើឡើងតាមឋានានុក្រមនៃ គ.ជ.ភ.ខ.។

**ប្រការ ៤.-**

សម័យប្រជុំពេញអង្គរបស់ គ.ជ.ភ.ខ. ប្រព្រឹត្តទៅរៀងរាល់ថ្ងៃពុធ ចាប់ពីម៉ោង ១៤:៣០នាទី រហូតដល់ម៉ោង ១៧:៣០នាទី។ ក្នុងករណីចាំបាច់ ការប្រជុំនឹងត្រូវប្រព្រឹត្តទៅពីរដងក្នុងមួយសប្តាហ៍។ ការប្រជុំនឹងអាចដំណើរការបានលុះត្រាតែមានកូរ៉ុមលើសពី៥០% នៃចំនួនសមាជិកគ.ជ.ភ.ខ. ទាំងមូល។ បើកូរ៉ុមខាងលើមិនគ្រប់ទេ ប្រធាន អង្គប្រជុំចេញលិខិតរំឭក អញ្ជើញប្រជុំនៅសប្តាហ៍បន្ទាប់។

**ប្រការ ៥.-**

ការសម្រេចទាំងប៉ុន្មាននៃសម័យប្រជុំនឹងយកជាការបាន លុះណាបានសំឡេងភាគច្រើនដាច់ខាត (ពាក់កណ្តាលបូកមួយ) នៃសមាជិកចូលរួមបោះឆ្នោត។ ឥស្សរជនដែលមានឈ្មោះក្នុងអនុក្រឹត្យស្តីពីការបង្កើត គ.ជ.ភ.ខ. តំណាង

អចិន្ត្រៃយ៍នៃក្រសួងឬស្ថាប័ន និង ប្រធានគណៈកម្មការបច្ចេកទេសពាក់ព័ន្ធនានា សុទ្ធតែមានសិទ្ធិបោះឆ្នោតសម្លេងមតិ។ កាលណាមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំមានឧត្តមានុភាព។

**ប្រការ ៦.-**

លេខាធិការនៃគ.ជ.ភ.ខ. មានភារកិច្ចធ្វើកំណត់ហេតុនៃការប្រជុំ គ.ជ.ភ.ខ. ដោយអាចសុំមន្ត្រីជំនួយការពីលេខាធិការដ្ឋានអចិន្ត្រៃយ៍។ បន្ទាប់ពីសម័យប្រជុំ លេខាធិការត្រូវយកលទ្ធផលដែល គ.ជ.ភ.ខ. បានអនុម័តទៅសុំហត្ថលេខាឯកភាពពីប្រធានអង្គប្រជុំ ដើម្បីរក្សាទុកនិងចាត់ចែងបន្ត។

**ប្រការ ៧.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់ថ្នាក់ដឹកនាំ ជាអង្គភាពជំនួយការរបស់ គ.ជ.ភ.ខ.ទាំងការងាររដ្ឋបាល ទាំងហិរញ្ញវត្ថុ និង ការងារផ្សេងៗទៀត។

**ប្រការ ៨.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវស្វែងរកសំណើកែលំអនិងអនុសាសន៍ល្អៗពីគ្រប់មជ្ឈដ្ឋាន ក្រោយពីព្រឹត្តិប័ត្រ ត្រូវបានផ្សព្វផ្សាយរួចហើយ ដើម្បីឱ្យ គ.ជ.ភ.ខ. មានលទ្ធភាពធ្វើសំយោគនិងដាក់លទ្ធផលស្ថាពរជូនប្រធាននៃ គ.ជ.ភ.ខ. ពិនិត្យមុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រេចឱ្យប្រើប្រាស់ទូទាំងប្រទេស។

លទ្ធផលស្ថាពរដែលត្រូវបានប្រកាសឱ្យប្រើទូទាំងប្រទេស ត្រូវចងក្រងជាសទ្ទានុក្រម ដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយ។

**ប្រការ ៩.-**

អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. មានភារកិច្ចចាត់ចែងធ្វើគម្រោងថវិកាជាតិ សម្រាប់ដំណើរការ គ.ជ.ភ.ខ. ស្របតាមមាត្រា៥នៃអនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។

គណៈកម្មាធិការនេះ ត្រូវស្វះស្វែងរកជំនួយឧបត្ថម្ភ ពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និង ពីប្រភពផ្សេងៗទៀត។

**ប្រការ ១០.-**

គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវបង្កើតគណៈកម្មការបច្ចេកទេស ដែលមានជាអាទិ៍ :

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ និង គណៈកម្មការបច្ចេកស័ព្ទផ្សេងៗ។ គណៈកម្មការបច្ចេកស័ព្ទអាចបង្កើតអនុគណៈកម្មការឯកទេសតាមសេចក្តីត្រូវការ។

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណានត្រូវស្វែងរកឯកភាពក្នុងការសរសេរពាក្យនិងក្នុងការអានពាក្យ។ គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ ត្រូវផ្អែកលើមូលដ្ឋានវេយ្យាករណ៍ជាក់លាក់ ដើម្បីកំណត់គោលការណ៍នៃការបង្កើតពាក្យថ្មី សម្រាប់ឱ្យគណៈកម្មការបច្ចេកស័ព្ទផ្សេងៗអនុវត្តតាម។ ចំពោះពាក្យកម្ចី គណៈកម្មការនេះក៏ត្រូវស្វែងរកនិងកំណត់គោលការណ៍ជាក់លាក់ ផ្អែកលើមូលដ្ឋានវេយ្យាករណ៍ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដូចគ្នាដែរ ដែលតម្រូវឱ្យអ្នកប្រើប្រាស់ភាសាអនុវត្តតាម ដើម្បីចៀសវាងភាពអនាធិបតេយ្យក្នុងភាសាខ្មែរ ជាពិសេសក្នុងការប្រើប្រាស់ជាសាធារណៈ តាមសាលារៀន តាមវិទ្យុ តាមទូរទស្សន៍ និង តាមការបោះពុម្ពផ្សាយ។

គណៈកម្មការបច្ចេកទេសនីមួយៗ ត្រូវមានអ្នកជំនាញមុខវិជ្ជាជាប្រធាន និង អ្នកភាសាវិទ្យាមួយ ឬ ពីរនាក់ ជាសមាជិកសម្រាប់ជួយបំភ្លឺបញ្ហាភាសា។

ប្រធានគណៈកម្មការបច្ចេកទេស ជាសមាជិករាយការណ៍សម្រាប់លទ្ធផលនៃគណៈកម្មការរបស់ខ្លួន ក្នុងសម័យប្រជុំនៃ គ.ជ.ភ.ខ.។

បទបញ្ជាផ្ទៃក្នុងនេះត្រូវបាន គ.ជ.ភ.ខ.អនុម័តបញ្ចប់
នៅថ្ងៃពុធ ទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរបស់ខ្លួន។

រាជធានីភ្នំពេញ ថ្ងៃ 24 ខែ 12 ឆ្នាំ២០០៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**